# ត្រសក់ចំណារ

## I. ស្ថានភាពទូទៅ

ដំណាំត្រសក់ត្រូវបានគេជឿជាក់ថាមានប្រភពនៅប្រទេសឥណ្ឌាក្រោយមកក៏ រីករាលដាលទៅប្រទេសអេស៊ីប ប្រទេសក្រិច ចិន ឥណ្ឌូនេស៊ី ប្រទេសថៃ និងនៅទ្វីបអាមេរិក។





ដំណាំប្រភេទនេះ គេចាត់បញ្ចូលទៅក្នុងដំណាំត្រូវការអាកាសធាតុក្តៅមធ្យម ចន្លោះ 18 - 30 °C ។

- ត្រសក់ចំណារស្ថិតក្នុងលំដាប់ Cucurbits គ្រួសារ Cucurbitaceae ឈ្មោះវិទ្យាសាស្ត្រ Cucumis sativus ឈ្មោះធម្មតាគឺ Cucurnber ។ គេចែកចេញជាពីរប្រភេទ គឺប្រភេទសំបករលោង និងសំបកគ្រើម ។ វាជាប្រភពនៃវីតាមីននិងសារធាតុរ៉ែផ្សេងៗជាច្រើនដូចជាសាច់បរិភោគ៨៣%ទឹក៩៦,៣ក្រាម ប្រូតេអ៊ីន០,៨៥ក្រាម ប្រេងខ្លាញ់០,៥ក្រាម ថាមពល១៣ គីឡូកាឡូរី Ca10 mg. P 25 mg. ដែក 1,5 mg និងវីតាមីនសេ ៧ មីលីក្រាម ក្នុងចំនួនទំងន់ ១០០ក្រាម ដែលអាចបរិភោគបានផ្លែខ្ចី ។

## II. បច្ចេកទេសដាំដុះ

- ដើម្បីទទួលបានទិន្នផលពីការដាំដុះ ដំណាំត្រសក់ក៏ដូចជាដំណាំឯទៀតដែរត្រូវមានការងារច្រើនដែលអនុវត្តន៍ដូចតទៅ:

### ១- ការជ្រើសរើសពូជ

✓ ការជ្រើសរើសពូជជាកត្តាសំខាន់បំផុត នៅក្នុងការដាំដុះព្រោះពូជមានលក្ខណៈផ្សេងៗពីគ្នា ហើយត្រូវបានចែកចេញជា ៣ ប្រភេទដូចតទៅ:

- ពូជស្រាល: ពូជនេះមានអាយុកាលលូតលាស់ខ្លីគឺប្រមាណពី៣៥ - ៤០ ថ្ងៃក្រោយដាំភាគច្រើនគឺផ្លែល្អិតតូចៗ ជាចង្កោមៗមាន បន្លាច្រើនជួរតាមបណ្តោយនៃផ្លែទទឹងផ្លែមិនលើស១,៥ស.មប្រវែងជាមធ្យម ៨-១០ ស.ម ។ សន្លឹកល្អិតដើម តូចផ្កាឈ្មោលច្រើនតាមថ្នាំង នៃដើមហើយមានរោមក្រាស់

លើផ្ទៃស្លឹក និងដើម គ្រាប់តូចល្អិតស្រួចៗហើយខ្លី ទំងន់ ១០០គ្រាប់មានចំនួន ២,៥-៤ក្រាមប្រភេទនេះគេឱ្យ ឈ្មោះថាត្រសក់បន្លា ឬត្រសក់ជ្រក់ ។

- ពូជកណ្តាល: ពូជនេះមានអាយុកាលលូតលាស់មធ្យម គឺប្រមាណពី ៤០ ទៅ៥០ថ្ងៃក្រោយដាំ ។ ផ្លែភាគច្រើនមានពណ៌បៃតងស្រាល ផ្នែកខាងគូទមានពណ៌ លឿងខ្ចី ផ្លែច្រើនរាយៗមិនចង្កោម ទទឹងផ្លែមានប្រវែង ៣-៤ស.ម បណ្តោយផ្លែប្រវែងពី ១០-១៣ស.ម រាងរបស់ផ្លែ វាធំកណ្តាល តូចក្បាល និងកន្ទុយពូជប្រភេទនេះកសិករភាគច្រើនដាំនៅតាមសួនបន្លែ មិនមានលក្ខណៈទ្រង់ទ្រាយជាផលិតកម្មធំៗឡើយ ព្រោះទិន្នផលរាប់ពី ៦-៨តោនក្នុង១ហាត ។ លក្ខណៈសំគាល់គឺ: ស្លឹកធំ ស្តើងរាងមូល ពោមខ្ចីៗមានពណ៌បៃតងធម្មតាគ្រាប់សំប៉ែតធំខ្លី ។

- ពូជធ្ងន់:ពូជនេះមានអាយុកាលលូតលាស់វែងប្រហែលពី៥០-៧០ថ្ងៃ





ក្រោយដាំ។ផ្លែរបស់វាទ្រវែងមានពណ៌បៃតងចាស់ប្រមាណ ២/៣ នៃប្រវែងផ្លែ ។ មានថ្នាំងរង្វើលបែកមែកមធ្យម ស្លឹកធំក្រាស់ ហើយស្រួចមានរោមរឹងទទឹងផ្លែជាមធ្យម ៣,៥ស.ម ប្រវែង ជាមធ្យម ១២-២០ស.ម រូបសណ្ឋាននៃគ្រាប់ទ្រវែងស្រួចកំប៉ោងកណ្តាលទំងន់ ១០០គ្រាប់ពី៣,៥-៥៥ក្រាមច្រើនដាំនៅខេត្តកណ្តាល កំពង់ឆ្នាំង និងកំពង់ចាម ។ ត្រសក់មិនមែនជាដំណាំប្រកាន់រដូវឡើយ ប៉ុន្តែពូជត្រសក់ក្រោយពីសំរាំងគ្រាប់ ហើយត្រូវការសំរាករយៈពេលពី ៤ -៦ ខែ ទើបអាចដាំដុះបាន ។ លក្ខណៈពិសេសមួយទៀតគឺបច្ចុប្បន្នមានពូជ ២ ប្រភេទគឺ ពូជគ្មានជំនាន់ អាចដាំហើយទុកពូជបាន ប៉ុន្តែពូជបង្កាត់ Hybrid $F_1$ មិនអាចទុកពូជបានឡើយ សេចក្តីត្រូវការពូជសំរាប់ដាំលើ ផ្ទៃដី ១ ហ.ត គឺ ៣,៥-៥ គ.ក្រ អាស្រ័យទៅតាម ភាគរយ ដំណុះ និងចន្លោះគុម្ពនៃការដាំ ។

## ២- ការជ្រើសរើសរដូវ

សំរាប់លក្ខខណ្ឌប្រទេសកម្ពុជាដំណាំត្រសក់មិនមែនដំណាំដែលប្រកាន់រដូវឡើយ វាអាយដុះលូតលាស់បានចន្លោះសីតុណ្ហភាពពី 20-30$^{o}$c។ ប៉ុន្តែរដូវសមស្របបំផុតគឺនៅចុងរដូវវស្សាចាប់ពីខែតុលា ដល់ ខែ កុម្ភៈ ព្រោះក្នុងអំឡុងពេលនោះត្រសក់អាចលូតលាស់ល្អ ទន្និផលខ្ពស់បណ្តាលមកពី កត្តាសីតុណ្ហភាពចុះទាប សំណើមបរិយាកាសខ្យល់ ភ្លៀងមិនអូសបន្លាយ សីតុណ្ហភាពដីប្រែប្រួលទាប រយៈពេលពន្លឺថ្ងៃមានកំរិតសមស្រប ។ ប៉ុន្តែត្រសក់ជួបកត្តាលំបាកជាច្រើន ចាប់ពីខែ មិនា ដល់ខែ ឧសភា គឺសត្វល្អិត ជំងឺបំផ្លាញច្រើន បណ្តាលមកពី លក្ខខណ្ឌអាកាសធាតុមិនសមស្រប ធ្វើអោយត្រសក់មានទិន្នផលទាប ។ តែនៅរដូវវស្សាវិញចាប់ពី ខែ មិថុនា ដល់ខែ កញ្ញា ត្រសក់ច្រើនជួបជំងឺបំផ្លាញ ច្រើនជាងសត្វល្អិត បណ្តាលមកពីសំណើមដី និង សីតុណ្ហភាពដីប្រែប្រួល ។

### ៣- ការជ្រើសរើស និងរៀបចំដី

- ការជ្រើសរើសដី: ត្រសក់ត្រូវការដីមានជីជាតិគ្រប់គ្រាន់ សំបូរទៅដោយសារធាតុចិញ្ចឹម និងបន្ទុកខ្យល់គ្រប់គ្រាន់សម្រាប់ត្រសក់ គឺដីប្រភេទដីល្បាប់មាត់ ស្ទឹង បឹង ទន្លេ និងដីល្បាយខ្សាច់មិនដក់ទឹកក្រោយពេលភ្លៀងធ្លាក់ កាលណាទឹកដក់ លើសពី៤ម៉ោងឡើងទៅធ្វើឱ្យ ត្រសក់ងាយកើតជំងឺទុំស្លឹក ។ ក្រៅពីនោះវាអាចលូតលាស់ល្អដែរនៅលើប្រភេទដីក្រហម និងដីខ្មៅក្នុងតំបន់ខ្ពង់រាបប៉ុន្តែដីឥដ្ឋ ឬ ដីជូរត្រសក់ លូតលាស់មិនល្អឡើយ ។ កាលណាដីដែលធ្លាប់ដាំដំណាំប្រភេទអំបូរ ត្រសក់ជាច្រើនលើករួចមក គេត្រូវបន្ថែមជីលាមកសត្វជាច្រើនតោនក្នុង ១ ហ.ត ចន្លោះពី ២០-៣០តោន ។ ដីដែលសមស្របខ្លាំងមាន pH ៦,៥-៧,៥ កាលណា pH ទាបជាង៤ ត្រូវផ្អាកការដាំត្រសក់រយៈពេល ១-២ឆ្នាំ ត្រូវដាំដំណាំអំបូរសណ្តែក ដើម្បី កែលំអដី ។

-ការរៀបចំដី: ត្រូវរាស់ប្រមូលយកស្មៅ និងដំណាំផ្សេងៗពីរដូវមុនចេញ ភ្ជួរហាលដីលើកទី១ ឱ្យជ្រៅត្រឡប់ស្រទាបពីក្រោមឡើងលើ និងហាលដីឱ្យបានច្រើនសប្តាហ៍ ក្នុងគោលបំណងបន្ថយនូវភ្នាក់ងារចម្លងជំងឺ និងសត្វល្អិតព្រមទាំងឱ្យ





ស្មៅចង្រៃងាប់ជាពិសេសគឺប្លូរ ទំរង់ដី និងពង្រាយជីជាតិ ។ ការភ្ជួរត្រូវធ្វើឱ្យបាន ២-៣ លើកមុននឹងលើករងដាំដុះ ។ ការលើករងសំរាប់ដាំ គឺអាស្រ័យទៅតាមវិធីដាំ និងជីជាតិរបស់ដី ។ កាលណាដាំដោយដោតចំបញ្ឆរ ទទឹងរងត្រូវមានប្រវែង ១២០សម កំពស់រង ២៥-៣០ស.ម ។ ប៉ុន្តែបើដាំឱ្យវានៅលើដីទទឹងរងមានប្រវែង ពី ៨០-១០០ ស.មតែការដាំតាមវិធីនេះត្រសក់មានផ្លែចំនួនតិចទិន្នផលទាប ។

នៅក្នុងលក្ខណខណ្ឌអាកាសធាតុក្តៅ ដីរក្សាសំណើម គ្របដីមុនពេលដាំដើម្បីបន្ថយកំដៅដី ស្មៅរក្សាសំណើមបានយូរ និងធ្វើឱ្យដីធូរ មិនហាប់ កាលណាដីហាប់បណ្តាល ឱ្យបន្ទុក ខ្យល់ $O^2$គ្រប់គ្រាន់និងប្រវែងឬសចាក់បានតិច ។

### ៤- វិធីសាស្ត្រដាំដុះ

- មុននឹងដាំត្រូវយកគ្រាប់ពូជមកដាក់ហាលថ្ងៃឱ្យក្តៅរយៈពេល ១-២ ម៉ោង បន្ទាប់មកយកទៅត្រាំទឹករយៈពេល៤-៥ម៉ោងបន្ទាប់ មកត្រូវលាងសំអាតគ្រាប់អោយស្អាត ចំនួន ៣-៤លើកមុនពេលផ្អាប់ត្រាំគ្រាប់ពូជ ។ ការផ្អាប់ត្រូវយក ក្រណាត់ជ្រលក់ទឹកឱ្យជោគយកមកខ្ចប់គ្រាប់នោះ ហើយកប់ទៅក្នុងដីសើមៗរយៈ ពេល១យប់ ។ មុនដាំត្រូវយកគ្រាប់ពូជមកលាយជាមួយនឹងថ្នាំសំលាប់ផ្សិតប្រភេទCaptan Zinneb Mancozeb ក្នុងកំរិត ២% ឬ ១គក្រ គ្រាប់ពូជបរិមាណ ថ្នាំកន្លះស្លាបព្រាបាយ ច្របល់ឱ្យសព្វយកទៅដាំ ដោយប្រើចន្លោះគុម្ព ២៥សម ចន្លោះជួរ ៦០ស.ម ជំរៅ ២-៣ ស.ម ២-៣ គ្រាប់ក្នុងមួយគុម្ព ហើយគ្របពីលើ ដោយកំណាត់ចំបើងខ្លីៗឬជីធម្មជាតិពុករលួយល្អ ពីវិធីនេះគឺដាំឱ្យត្រសក់ឡើងតោង

ចំណារបញ្ឈរ ប៉ុន្តែការដាំឱ្យវារលើដីត្រូវប្រើចន្លោះជួរ៨០ស.មចន្លោះគុម្ព ៥០ស.ម ៣-៤ គ្រាប់ក្នុងមួយ គុម្ព ៥០ស.ម, ៣-៤ គ្រាប់ ក្នុងមួយគុម្ព តែគ្របគុម្ព ដូចគ្នា ក្រោយពីដាំភ្លាមត្រូវពិនិត្យមើលសំណើមដីកាលណាដីស្ងួតខ្លាំងត្រូវតែស្រោចទឹកក្រោយដាំហើយដើម្បីឱ្យត្រសក់ដុះស្មើគ្នាងាយថែទាំ ។ ក្រោយពីដាំរយ:ពេល ៣-៤ ថ្ងៃក្នុងលក្ខខណ្ឌអាកាសធាតុពេលថ្ងៃ ៣០ °C និង ពេលយប់ ១៨-២០ °C ធ្វើឱ្យត្រសក់លូតលាស់លឿន ។

### ៥- របៀបស្រោចស្រព

- **ដំណាំត្រសក់:** ជាប្រភេទដំណាំត្រូវការទឹកជាប្រចាំ ប៉ុន្តែសំណើមដីមិនលើសពី ៥០-៧០% ឡើង ។ សេចក្តីត្រូវការទឹកចែកចេញ ជាបីវគ្គ ៖

- **វគ្គលូតលាស់:** ចាប់ពីត្រសក់ដុះ រហូតដល់ត្រសក់បោះដៃ និងមានផ្កាក្រពុំវាត្រូវការសំណើមដីជា មធ្យមប្រមាណពី ៥០-៦០ %។ របៀបស្រោចដោយបាញ់ទឹកពីលើល្អជាងការស្រោចដោយបញ្ចូលតាមចន្លោះជួរ គឺ ១ថ្ងៃម្តង ឬ២ដងទៅ តាមប្រភេទដី និងអាកាសធាតុ បរិមាណទឹកក្នុងវគ្គនេះមានប្រមាណពី ១៥០០ទៅ ១៦០០ ម$^{៣}$/ហត ។

- **វគ្គបន្តពូជ និងផ្លែ:** ចាប់ពីត្រសក់មានអាយុពី ១៥ថ្ងៃឡើងទៅ វានឹងមានផ្កាឈ្មោលចេញតាមថ្នាំង ប៉ុន្តែមិនទាន់រីក វគ្គនេះវាត្រូវការសំណើមដីពី ៦០ -៧០% គឺជាវគ្គដែលត្រូវការទឹកច្រើនជាងគេ រហូតដល់ត្រសក់មានអាយុ ៣០-៤០ ថ្ងៃក្រោយដាំ ប៉ុន្តែការស្រោចដោយបញ្ចូលតាមចន្លោះរងមួយអាទិត្យ ២-៣ លើក



ជាការល្អព្រោះការស្រោចដោយបាញ់ ទឹកពីលើធ្វើឱ្យប៉ះពាល់ដល់ការបន្តពូជ បរិមាណទឹកបរិសុទ្ធ ក្នុងវគ្គនេះមានពី ១៨០០-២០០០ម៣/ហត ។

- **វគ្គចេញផ្លែ:** ១០០% ចាប់ពីការប្រមូលផលបាន ១-២ លើកត្រសក់ត្រូវ ការសំណើមដីទាបមកវិញ គឺពី ៥០-៦៥% កាលណាការ បញ្ចូលទឹកលើសពីនេះធ្វើ ឱ្យត្រសក់ចាប់ប្រែពណ៌បៃតងទៅលឿង ។

### ៦- ដកស្មៅ និងជ្រំជ្រោយដី

- ការជ្រំជ្រោយដីត្រូវធ្វើឡើងនៅពេលត្រសក់មានសន្លឹកពិតចំនួន ២ គឺនៅពេលទងរបស់វាលូតវែង (១០-១៥ថ្ងៃក្រោយដាំ) ត្រូវជ្រំបំបែកដីសើរៗ ហើយ កៀរដីពីបាតរងមកលប់គល់ឱ្យជិតក្នុងករណីដីដែលដុះស្មៅត្រូវដកយកស្មៅចេញ មុនជ្រំជ្រោយដី ។ ចំពោះការដាំ ដោយគ្របនឹងកៅស៊ូខ្មៅ មិនចាំបាច់ជ្រំជ្រោយដីឡើយ ។ ការជ្រំជ្រោយដី គឺប្រយោជន៍ធ្វើឱ្យដីធូរមិនចាំបាច់ជ្រំជ្រោយដីឡើយ ។ ការជ្រំជ្រោយដីគឺប្រយោជន៍ធ្វើឱ្យដីធូរ ជ្រាបទឹកបានល្អរក្សាសំណើមបានយូរធ្វើឱ្យខ្យល់ចេញចូលបានល្អបន្ថយការលូតលាស់របស់ស្មៅ ។

### ៧- ការដោតចំណារ

ការដោតចំណោរមានសារ:សំខាន់ដោយ បង្កើនទិន្នផល និងបន្ថយការរាតត្បាតអំពីជម្ងឺ និងសត្វល្អិត ។ ការដោតចំណារត្រូវយកមែកឈើក្រៀមៗគ្មានស្លឹកមកដោយបញ្ឈរក្បែរៗគុម្ពឱ្យញឹកហើយចងឱ្យជាប់ការពារដួលរលំគេធ្វើឡើងក្រោយពីដាំរយ:ពេល ១០-១៥ថ្ងៃ គឺក្រោយពីជ្រំជ្រោយដី ។